- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ឆូច ស៊ាងតាណា** ជាសមាជិក ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី 31 ខែ 12 ឆ្នាំ 2001

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

លេខ : ០៦ ច.ល

**ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង៉ី ត៉ាន់

ករល-០១.១២-០០៥៩

# ព្រះរាជក្រឹត្យ

យើង

នស / រកត / ១២០១/៤៦៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ឯកឧត្តម ញឹក ប៊ុនឆៃ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម ខាំ សង្វាតធីវង្ស ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ ព្រឹទ្ធសភា ទទួលបន្ទុកការងារទំនាក់ទំនងជំនួយមនុស្សធម៌ក្នុងប្រទេស និងក្រៅប្រទេសមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២:** ឯកឧត្តម ខាំ សង្វាតធីវង្ស ស្ម័គ្រចិត្តបំរើការងារដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ៣:** ប្រធានព្រឹទ្ធសភាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា លេខ : ០៥ ច.ល

ជា ស៊ីម

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន

៣រព. ០១.១៧.០០៦០

នស/រកត/១២០១/៤៦៦

# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- យោងតាមអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- យោងតាមអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការបំពេញបន្ថែមខ្លឹមសារ ក្នុងមាត្រា ១៥ ជំពូកទី ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរបញ្ចូលក្នុងឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវឯកឧត្តម លោកជំទាវ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - ឯកឧត្តម ស ខេង | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ២ - ឯកឧត្តម យូ ហុកគ្រី | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ៣ - ឯកឧត្តម ស៊ឹម កា | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ៤ - ឯកឧត្តម ព្រុំ សុខា | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៥ - ឯកឧត្តម ខូច ម៉េងហ៊ាន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៦ - ឯកឧត្តម នុត សោររាន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៧ - ឯកឧត្តម ហ៊ុន ណេង | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៨ - ឯកឧត្តម ជា សុផារ៉ា | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៩ - ឯកឧត្តម ជៀង អំ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១០ - ឯកឧត្តម អ៊ុង សាមី | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១១ - ឯកឧត្តម ស្វ ភឿង | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១២ - ឯកឧត្តម ស៊ូ ភិរិន្ទ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៣- ឯកឧត្តប យុទ្ធ ភូថង | បាននួរសក្តិឧត្តបបន្ត្រី | ថ្នាក់លេខ ២ |
| ១៤ - ឯកឧត្តម កែប ជុតិមា | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៥ - ឯកឧត្តម ថាច់ ឃន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៦ - ឯកឧត្តម ប្រាជ្ញ ចន្ទ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៧ - ឯកឧត្តម ឃួណ លឹមហេង | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៨ - ឯកឧត្តម ចង សុត្រា | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ១៩ - ឯកឧត្តម ឃឹម ឆូរ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២០ - ឯកឧត្តម អោន ហោ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២១ - ឯកឧត្តម ខួន ម៉ើន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២២ - ឯកឧត្តម ស្បោង សារ៉ាត់ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២៣ - ឯកឧត្តម ស៊ុក សំអេង | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២៤ - ឯកឧត្តម ស៊ឹម សុន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ២៥ - ឯកឧត្តម ស្លា ប្រយុទ្ធ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ២៦ - លោកជំទាវ និន សាផុន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ២៧ - ឯកឧត្តម ឆោម ប៊ុនខន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ២៨ - ឯកឧត្តម ផ្លោក ផន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ២៩ - ឯកឧត្តម អ៊ុំ សារិទ្ធ | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៣០ - ឯកឧត្តម ម៉ោញ ភុសល | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៣១ - ឯកឧត្តម ហែម ខន | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៣២ - ឯកឧត្តម អោក ប៊ុន្នី | បាននួរសក្តិឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |

៣៣ - ឯកឧត្តម **ខូយ ឃុនហួរ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៤ - ឯកឧត្តម **ឆាំង ហមផាន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៥ - ឯកឧត្តម **ទូច ម៉ារីម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៦ - ឯកឧត្តម **ម៉ប់ សារិន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៧ - ឯកឧត្តម **ចេង គីមហេង** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៨ - ឯកឧត្តម **ហេះ ភាន់** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៣៩ - ឯកឧត្តម **ម៉ែន សូខូយ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
៤០ - ឯកឧត្តម **សក់ សេដ្ឋា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤១ - ឯកឧត្តម **លី ស៊ូ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤២ - ឯកឧត្តម **ញៀម សាម៉ិន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤៣ - លោកជំទាវ **សុខ សំណាង** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤៤ - ឯកឧត្តម **ខៀវ ជា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤៥ - ឯកឧត្តម **លេង វី** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៤៦ - ឯកឧត្តម **ពុង មន្តារិទ្ធ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៧ - ឯកឧត្តម **ឃ្លោក ប៊ុតឌី** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៨ - ឯកឧត្តម **ចាប ញ៉ាលីវុធ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៩ - ឯកឧត្តម **ឆេព នន្ទីរ** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥០ - ឯកឧត្តម **អ៊ិត ដេតតូឡា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥១ - ឯកឧត្តម **សាយ ហាក់** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥២ - ឯកឧត្តម **នុច ថន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៣ - ឯកឧត្តម **អ៊ុយ ស៊ីម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៤ - ឯកឧត្តម **ម៉ុល លឹម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៥ - ឯកឧត្តម **ឆាយ សាវ៉េត** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៦ - ឯកឧត្តម **ឈឹម ធាម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៧ - ឯកឧត្តម **ភង ហ៊ាង** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៨ - ឯកឧត្តម **ឈុន ស៊ីរុន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៩ - ឯកឧត្តម **ឡុង សុវណ្ណា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦០ - ឯកឧត្តម **ឡាយ សុខា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦១ - ឯកឧត្តម **ភោគ សំអេន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦២ - ឯកឧត្តម **អាយ ខន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៣ - ឯកឧត្តម **ង៉ាល់ សាន្ត** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៤ - ឯកឧត្តម **ឃឹម សុខុម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦៥ - ឯកឧត្តម គី សារ៉ា បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦៦ - ឯកឧត្តម ប៊ិច ស៊ុខិន បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦៧ - ឯកឧត្តម ស៊ិន ហេង បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦៨ - ឯកឧត្តម ណារ៉ាំ នុំ បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦៩ - ឯកឧត្តម ក្រុយ សារឹម បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៧០ - ឯកឧត្តម អ៊ែម ម៉ុនផុល បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៧១ - ឯកឧត្តម ញ៉ា វ៉ិចចាន់ បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

៧២ - លោកជំទាវ ដេន គីម បានទទួលសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្វបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ពរល.០១-១២-០០៦១

លេខ : ០២៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

នស/រកត/១២០១/៤៦៧

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- យោងតាមអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការ ស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរបញ្ចូលក្នុងឋានន្តរសក្តិវរៈមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវលោក លោកស្រី ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - លោក សៅ សារឿន | ឋានន្តរសក្តិវរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២ - លោក គីម ណាំង | ឋានន្តរសក្តិវរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៣ - លោក សួស ភារណាន | ឋានន្តរសក្តិវរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៤ - លោក ប៉ាល់ សំអឿន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៥ - លោក សួន សារិទ្ធ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៦ - លោក ស្រី មណ្ឌល | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៧ - លោក ជី ហួត | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៨ - លោក ប្រាក់ សាវុធ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ៩ - លោក សួរ ណារាត | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១០ - លោក រ័ត្ន សារិន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១១ - លោក ឡាច សួគី | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១២ - លោក អ៊ុង ម៉ុន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៣ - លោក អែល សយ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៤ - លោក អ៊ិច សារូ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៥ - លោក ចៅ សុផុន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៦ - លោក អ៊ុង អៀវ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៧ - លោក ភារ លាន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៨ - លោក ស៊ូ ហ្សុរភារីយ៉ា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ១៩ - លោក ជ័យ សាយឿន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២០ - លោក ម៉ក់ សំអឿន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២១ - លោក ម៉ាន់ ទុច | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២២ - លោក ខួន ឡុន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៣- លោក ហ៊ុង សារិទ្ធ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៤ - លោក កើត សុធា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៥ - លោក ជិន សុធា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៦ - លោក ឈុន ឈន់ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៧ - លោក ហាយ សួន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៣ |
| ២៨ - លោក ខេត ចន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៤ |
| ២៩ - លោក ខេម ហ៊ាញ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៤ |
| ៣០ - លោក វាយ គីម | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៤ |
| ៣១ - លោក សៀក ជីវឡៀង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៤ |
| ៣២- លោក ម៉ិន ស៊ាន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៤ |

៣៣ - លោក គុជ ឆៃលិម ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៤ - លោក ខាំ ភឿន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៥ - លោក ឡឿ សុផល ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៦ - លោក យឹម សិលា ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៧ - លោក ជាម ហ៊ីម ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៨ - លោក ឡុង ហ៊ីម ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៣៩ - លោក ជុំ ប៊ុនរ៉ុង ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤០ - លោក សំ សាន្ត ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤១ - លោក ឡាន់ ឆន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤២ - លោក អ៊ុយ ខេមរា ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៣ - លោក យឹម ធិន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៤ - លោក សៀង ស៊ុតថង ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៥ - លោក នាង នៅ ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៦ - លោក មាស សារម៉េត ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៧ - លោក សើរ កុសល ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៨- លោក ណៅ ណៃ ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៤៩ - លោក សំ ថា ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥០ - លោក មឿង កែល ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥១ - លោក អៀង ទុធ ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥២ - លោក ច័ន្ទ សំអាន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៣- លោក ឆា សុជាតិវង្ស ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៤- លោក ច្រាក់ ស៊ីហារ៉ា ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៥ - លោក សោម សុផាត ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៦ - លោក កែវ ហន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៧ - លោក ឈិត សុខុន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៨ - លោក សំ សារ៉ឹន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៥៩ - លោក អ៊ុង ច័ន ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៦០ - លោក ឡេង លឿង ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៦១ - លោក គីម ឆា ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៦២ - លោក ឆោង បុផារិទ្ធ ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៦៣- លោក សែន សំភី ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

៦៤ - លោក កុល វីរក្ស ឋានន្តរសក្តិ វរៈមន្ត្រី ថ្នាក់លេខ ៤

| | | |
|---|---|---|
| ៦៥ - លោក ម្ហូង ម៉ៃ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៦៦ - លោក ទៀ ប្រុង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៦៧ - លោក ទេវ ចណ្ណលិ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៦៨ - លោក ហួយ គីចឡៀនៈ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៦៩- លោក ខាន់ ទ៊ា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧០ - លោក ខូយ សុខា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧១ - លោក ស៊ុយ សាន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧២ - លោក ឌី គីមតុក | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៣- លោក យិន សុទិនចិន្តា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៤- លោក អេង មង្គល | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៥ - លោក ឌី សុភផាន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៦ - លោកស្រី ដួង ចណ្ណា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៧ - លោក កៅ ខុនដារ៉ា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៨ - លោក ថិន សំរួល | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៧៩- លោក ទុំ ចំរើន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨០ - លោក ចាន់ សាទ៉ាន់ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨១ - លោក គុម សារឿង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨២ - លោក ចំន្ទ សុផល | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៣- លោក សុខ សារីទុង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៤- លោក រស់ ចរុណា | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៥- លោក ឌុច សុន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៦ - លោក ដាញ់ អាង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៧ - លោក ញៀម សុខារ័ត្ន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៨ - លោក ម៉ែន ធឿន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៥ |
| ៨៩- លោក សួ សុខខេង | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩០ - លោក អ៊ែច សេន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩១ - លោក ហាស ទុស្សី | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩២ - លោក សំកុល សុខន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩៣ - លោក ប្រាក់ ឡឿន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩៤ - លោក ម៉ី សាម៉ន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩៥- លោក ភង ស៊ាន | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៦ |
| ៩៦ - លោក ឆាយ ចិនឡាយ | ឋានន្តរសក្តិ វរៈមន្ត្រី | ថ្នាក់លេខ ៧ |

៩៧ - លោក ឡាយ ទេវាហារិទ្ធ ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៧

៩៨ - លោក ស៊ុយ សេរិទ្ធ ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៧

៩៩ - លោក ពេជ ហាន ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៧

១០០ - លោក ជួរ ជេតថារិទ្ធ ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៧

១០១ - លោក ឡាច ស៊ីមរុន ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៧

១០២ - លោក ឆាន សុដល ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៨

១០៣ - លោក សរ ប៊ីណា ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៩

១០៤ - លោក ភាន់ ទុន្នី ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៩

១០៥ - លោក ចេង លីមស្រៀង ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៩

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

៣៧.០១.១២.០០៦២

លេខ : ០៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០០២

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ណាអី តាន់

នស/រកត/១២០១/៤៦៨

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- យោងតាមអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរបញ្ចូលក្នុងឋានន្តរសក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវអស់លោក ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - លោក តូច ញឹម | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ២ - លោក ឡៅ ប៊ុនធា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ៣ - លោក ឆ៊ាង ឆ៊ាន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ៤ - លោក សៀ និយម | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ៥ - លោក គៀន ថៃ | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ៦ - លោក មុំ ខេង | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៥ |
| ៧ - លោក សរ គីនីរ៉ា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៨ - លោក សុភ ខា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៩ - លោក ឈិន កេតនា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១០ - លោក វ័ន្ត អ៊ូ | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១១ - លោក ម៉ឿន សាម៉ន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១២ - លោក ប៊ុក ចន្ទ្រាឫទ្ធី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៣ - លោក ឈឹម នី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៤ - លោក ជិន លី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៥ - លោក ថី កេង | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៦ - លោក ហុង ផារិទ្ធ | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៧ - លោក ហាក់ ម៉ាត | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៨ - លោក ម៉ាន់ ហាំ | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ១៩ - លោក ជួប សុខន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២០ - លោក រាជ សុគន្ធ | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២១ - លោក ថោង ប៊ុនធឿន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២២ - លោក ហុង ស៊ីលីន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៣ - លោក ស៊ីន ណារាឌី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៤ - លោក ចាន់ សុវណ្ណា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៥ - លោក កែវ សែន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៦ - លោក ខៀវ សុខន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៧ - លោក ស៊ឹម សុវណ្ណី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៨ - លោក សោម ខាន់ដា | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២៩ - លោក ភុយ ប៊ុនសន | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៣០ - លោក ហ៊ុយ ឧក | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៣១ - លោក គាវ សុវណ្ណាធី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៣២ - លោក ខៀន រិទ្ធី | បរិញ្ញាបត្រ អនុមន្ត្រី | ថ្នាក់លេខ ៨ |

៣៣ - លោក ឈើម គឹមសាន ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ៨

៣៤ - លោក ឡាយ ពនារុធ ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ៨

៣៥ - លោក ម៉ែន ម៉ុនរិទ្ធ ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១០

៣៦ - លោក សុខ សារមឿន ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១១

៣៧ - លោក សុខ លីនណា ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១២

៣៨ - លោក សេង យូវ៉ាន់ ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១២

៣៩ - លោក សុខ វឿន ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១២

៤០ - លោក ម៉ែម ចន្ទណារ៉ី ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១៣

៤១ - លោក ខោល យុទ្ធលី ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១៣

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

៣រស-០១-១២-០០៦៣

លេខ : ០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបំពេញបន្ថែមខ្លឹមសារក្នុងមាត្រា ១៥ ជំពូកទី ៤ នៃអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១២៩៧ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :** ត្រូវបានបំពេញបន្ថែមខ្លឹមសារក្នុងមាត្រា ១៥ ជំពូកទី៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្រប

ខ័ណ្ឌថ្មី ដែលមានខ្លឹមសារដូចខាងក្រោម

- ចំពោះមន្ត្រីរាជការទាំងឡាយណា ដែលបានបំពេញការងារក្នុងមុខដំណែងជាអភិបាល-រងខេត្ត ក្រុង មានរយៈពេលចាប់ពី ៨ឆ្នាំជាប់គ្នាឡើង ហើយពុំមានការប្រែប្រួលក្នុងមុខដំណែងត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

__មាត្រា២__ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

__មាត្រា៣__ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០១

ហ៊ុន សែន

__ចំលងជូន__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...១៣០...អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៥៣ អនក្រ.បក

## ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពី វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រកាសចំពោះមុខរដ្ឋសភា នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨
- យោងតាមការចាំបាច់ក្នុងការជំរុញការអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍

## សំរេច

**មាត្រា១.** បន្ថែមក្នុងមាត្រា២ នៃអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ឧបសម្ព័ន្ធទី១ ភាគ ក នូវ : ចំណុចទី២៣ <ហេដ្ឋារចនាសម្ព័ន្ធបំរើអោយការវិនិយោគវិស័យទូរគមនាគមន៍ ដែលមានបច្ចេកវិទ្យាខ្ពស់> ។

**មាត្រា២.** លុបចេញពីមាត្រា២ នៃអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ឧបសម្ព័ន្ធទី១ ភាគ ខ នូវ : ចំណុចទី៩ <សេវាទូរគមនាគមន៍> ។

**មាត្រា៣.** ក្រៅពីការធ្វើវិសោធនកម្មក្នុងមាត្រាទី១ និងទី២ ខាងលើនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវរក្សាទុកជាធរមានដដែល ។

**មាត្រា៤.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៨ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- កាលប្បវត្ត - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៣១ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់កំរិតអតិបរមា នៃកំរៃអាជ្ញាប័ណ្ណ**

**សំរាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

*******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០១

**សំរេច**

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ អំពីកម្រិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ ។ ផ្អែកតាមកម្រិតអតិបរមានេះ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគណនាកម្រៃអាជ្ញាប័ណ្ណសំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដើម្បីធានាតុល្យភាពចំណូលចំណាយនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ។ អ្នកសុំអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់កម្រៃអាជ្ញាប័ណ្ណតាមការកំណត់របស់អាជ្ញាធរ ។

**មាត្រា ២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានបំណងធ្វើសេវាកម្មអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់

កម្រៃស្នើសុំអាជ្ញាប័ណ្ណ នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ កម្រៃស្នើសុំអាជ្ញាប័ណ្ណ គឺជាចំនួនទឹកប្រាក់ដែលអ្នកស្នើសុំ ត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ចំណាយ ដើម្បីអនុវត្តកិច្ចការរបស់អាជ្ញាធរ ក្នុងការពិនិត្យ វិភាគ ផ្សព្វផ្សាយពិគ្រោះយោបល់ និងចេញអាជ្ញាប័ណ្ណ ។ កម្រិតអតិបរមានៃកម្រៃស្នើសុំអាជ្ញាប័ណ្ណត្រូវកំណត់ដូចខាងក្រោម ៖

១. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីដែលមានលក្ខណៈអនុគ្រោះ (អគ្គិសនីជនបទ) កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីហាសិបពាន់រៀល (៥០ ០០០ រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

២. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតតូច តូចជាងប្រាំរយ (៥០០)គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីមួយរយពាន់រៀល (១០០ ០០០ រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

៣. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតមធ្យម ពីប្រាំរយ (៥០០) ទៅបីពាន់ (៣០០០)គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីប្រាំមួយរយពាន់រៀល (៦០០ ០០០រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

៤. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតធំ លើសពីបីពាន់ (៣០០០)គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីមួយលានរៀល (១ ០០០ ០០០ រៀល ) ក្នុងអាជ្ញាប័ណ្ណមួយ ។

កម្រៃស្នើសុំអាជ្ញាប័ណ្ណនេះ ត្រូវបង់តែម្តងគត់នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្វែរកម្រៃនេះជូនទៅអ្នកសុំវិញ ក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជា សម្រេចមិនផ្តល់អាជ្ញាប័ណ្ណឱ្យអ្នកស្នើសុំ ។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលកំពុងធ្វើសេវាកម្មអគ្គិសនី និងមានច្បាប់អនុញ្ញាតចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬចេញដោយអាជ្ញាធរណាមួយ របស់រាជរដ្ឋាភិបាលមុនពេលអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន អាចស្នើសុំអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ដោយពុំចាំបាច់បង់កម្រៃស្នើសុំអាជ្ញាប័ណ្ណឡើយ ។

**មាត្រា ៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលបានទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា អនុញ្ញាតឱ្យធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កម្រៃធ្វើសេវាកម្មក្រោមអាជ្ញាប័ណ្ណនេះ ជូនអាជ្ញាធរតាមការកំណត់របស់អាជ្ញាធរសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ កម្រៃនេះហៅថាកម្រៃអាជ្ញាប័ណ្ណ ។ កម្រៃអាជ្ញាប័ណ្ណគឺជាចំនួនទឹកប្រាក់ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ប្រចាំខែ ឱ្យអាជ្ញាធរចំណាយ លើកិច្ចប្រតិបត្តិការគ្រប់គ្រងសកម្មភាពសេវាកម្មអគ្គិសនីរបស់អាជ្ញាធរ ។ កម្រិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង់តាមប្រភេទសេវាកម្មនីមួយៗ មានដូចខាងក្រោម ៖

១. ការផលិតអគ្គិសនីឬការទិញអគ្គិសនីពីក្រៅប្រទេស ៖ កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី១,៧០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង នៃថាមពលបញ្ចេញ ឬទិញចូលឡើយ

២. ការបញ្ជូនអគ្គិសនី : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី០,៧០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលបញ្ជូនឡើយ

៣. ការចែកចាយនិងលក់អគ្គិសនី : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី១,២០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលលក់ឡើយ

៤. ការធ្វើសេវាកម្មលក់រាយ : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី០,៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលលក់ឡើយ

៥. ការធ្វើសេវាកម្មក្រោមអាជ្ញាប័ណ្ណផ្សេងៗទៀត ដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ស្តីពី អគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី ០,១ ភាគរយនៃថ្លៃសេវាកម្មឡើយ ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវកំណត់ឱ្យច្បាស់លាស់ នូវកម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្ម សំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ រួមទាំងវិធីគណនាកម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មនេះ នៅក្នុងគំរោងថវិកាប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ -កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ..១៣៧.....អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តនីព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីស្នងការគណនីនៃសហគ្រាសសាធារណៈ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០១

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ **ក្រុមហ៊ុនជាតិធានារ៉ាប់រង កម្ពុជា** ហៅកាត់ថា **កាមិនកូ** ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**កាមិនកូ** មានទីស្នាក់ការនៅរាជធានីភ្នំពេញ អគារលេខ ២៨ កាច់ជ្រុងផ្លូវលេខ ១៣ និងលេខ ១០៦ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កាមិនកូ** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាពផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**កាមិនកូ** ត្រូវស្ថិតក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២ .-**

**កាមិនកូ មានគោលដៅ និងភារកិច្ច ដូចខាងក្រោម :**

១- **កាមិនកូ** ធ្វើអាជីវកម្មធានារ៉ាប់រង សហធានារ៉ាប់រង និងធានារ៉ាប់រងបន្ត លើគ្រប់ប្រភេទហានិភ័យ រួមទាំងធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងលើអាយុជីវិត ។

២- អនុវត្តគ្រប់កិច្ចការដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងអាជីវកម្មធានារ៉ាប់រង សហធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ។

៣- ចូលរួមតាមគ្រប់មធ្យោបាយជាមួយសហគ្រាស ឬក្រុមហ៊ុនទាំងឡាយដែលកំពុងដំណើរការ ឬជាមួយក្រុមហ៊ុនដែលនឹងដំណើរការនាពេលខាងមុខ ដូចជា ចូលហ៊ុន ចុះកិច្ចសន្យាពាណិជ្ជកម្ម ទិញភាគហ៊ុន និងចូលរួមរាល់កិច្ចការ ឬសហគ្រាសទាំងឡាយដែលផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍របស់ក្រុមហ៊ុន។

៤- ចូលរួមរាល់ប្រតិបត្តិការឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ចលនទ្រព្យ ឬ អចលនទ្រព្យផ្សារភ្ជាប់ដោយចំពោះ ឬមិនចំពោះ ទៅនឹងគោលបំណងរបស់ក្រុមហ៊ុន ឬអាចសម្រួលដល់សមិទ្ធផល និងការរីកចំរើននៃប្រតិបត្តិការខាងលើ ។

៥- ទទួលខុសត្រូវនិងចាត់ចែង ក្នុងការងារការពារសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់លើការងាររបស់ខ្លួន។

៦- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចគ្នានឹងអាជីវករ ។

៧- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពអោយមានប្រសិទ្ធភាព និងមានការរីកចំរើន ។

៨- **គាមិនភូ** ទទួលពីរដ្ឋនូវសិទ្ធិនិងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

**មាត្រា ៣ .-**

**គាមិនភូ** ត្រូវគោរពរបបពន្ធ និងអាករ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤ .-**

ដើមទុនដំបូងរបស់ **គាមិនភូ** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលទទួលបាននូវការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **គាមិនភូ** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលរដ្ឋបានប្រគល់ឱ្យ ហើយដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៥ .-**

បុគ្គលិករបស់ **គាមិនភូ** ត្រូវជ្រើសរើសពីចំណោមមន្ត្រីរាជការ នៃមុខងារសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាចជ្រើសរើសបុគ្គលិកខាងក្រៅបើយល់ឃើញថាចាំបាច់ ។ បុគ្គលិករបស់ **គាមិនភូ** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក អនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២

## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា ៦ .-**

**គាមិនភូ** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | ជាប្រធាន |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| -តំណាងក្រសួងយុត្តិធម៌ | ១រូប | ជាសមាជិក |
| -អគ្គនាយក **គាមិនភូ** | | ជាសមាជិក |
| -តំណាងនិយោជិតរបស់ **គាមិនភូ** | ១រូប | ជាសមាជិក |

**មាត្រា ៧ .-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ)ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច ឬនីតិសាស្ត្រ ឬពាណិជ្ជសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់ និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **ភាមិនភូ**។

**មាត្រា ៨ .-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាម **ភាមិនភូ** ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុរបស់សហគ្រាស ត្រូវគោរពច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :**

១- ផ្តល់ការយល់ព្រមលើគំរោងផែនការសហគ្រាស ដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យនេះ

២- វាយតម្លៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសំរួលឱ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រម លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សេដ្ឋកិច្ច **ភាមិនភូ** ។

៤- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **ភាមិនភូ** ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទ ដូចមានចែងក្នុងបទបញ្ជាជាធរមាន ។

៦- សម្រេចបង្កើត បើក ឬបិទភ្នាក់ងារ សាខា ឬការិយាល័យរបស់ **ភាមិនភូ** តាមការវិនិច្ឆ័យរបស់ខ្លួន។

៧- ផ្តល់ការយល់ព្រមលើសំណើ នៃការបណ្តាក់ទុនសម្រាប់មូលនិធិធំនេររបស់ក្រុមហ៊ុន ។

៨- ផ្តល់ការយល់ព្រមលើសំណើទិញ ផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយមានវត្ថុបញ្ចាំ ឬដោយគ្មានវត្ថុបញ្ចាំ ឬការធានាផ្សេងៗទៀត លើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។

**មាត្រា ៩ .-**

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេលវេលា អាស្រ័យដោយអត្ថប្រយោជន៍របស់សហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក ដែលមានចំនួនបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ ដង ក្នុងរយៈពេល ៣ ខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានក្នុងអង្គប្រជុំ ចាត់ចែងបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃអង្គប្រជុំ ព្រមទាំងឯកសារ ដែលទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិចបីនាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយ ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះណាតែមានការអនុម័ត ដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១០ .-**

សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ និងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥ ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រជាហូរហែរ និងមានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើមត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលវត្តមាន និងលេខាធិការជ្រើសរើសដោយអគ្គនាយក ។

**មាត្រា ១១ .-**

អគ្គនាយកមានភារកិច្ចគ្រប់គ្រងការងារនៃ **ការមិនគ** ជាប្រក្រតី និងត្រូវបានតែងតាំងសម្រាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ តំណែងនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១២ .**

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ តំណាងឱ្យ **ការមិគ** និងទទួលខុសត្រូវចំពោះមុខតុលាការ ។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកមានភារកិច្ច :

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ សម្រេច និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមតំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ភាមិនភ្វ** ។

២- ទទួលបន្ទុកដឹកនាំ **ភាមិនភ្វ** ផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវាកម្ម និង ហិរញ្ញវត្ថុ ។

៣- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណាង ឬបញ្ឈប់ការងារ និងមានសិទ្ធិត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ភាមិនភ្វ** ដោយគោរពតាមលក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៥- តំណាងឱ្យ **ភាមិនភ្វ** នឹងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់តវ៉ា ការពារក្តីឱ្យ **ភាមិនភ្វ** និងប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៣ .-**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៤ .-**

ការចុះនិងការអនុវត្តកិច្ចសន្យាដោយ **ភាមិនភ្វ** ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន ។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៥ .-**

**ភាមិនភ្វ** កាន់កាប់គណនេយ្យរបស់ខ្លួន ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដដែល។

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី ៣១ ខែមិនានៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃ ព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ។

**មាត្រា ១៦ .-**

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការ ប្រចាំឆ្នាំរបស់ **ភាមិនភ្វ** តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ .-**

ធនធាននៃ **ភាមិនភ្វ** ជាអាទិ៍មាន :

-ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យ (តុល្យការដំបូងនៅពេលបង្កើត)

-ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម

-ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ភាមិនភ្វ**

-ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុ របស់ **ភាមិនភ្វ**

-ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា ១៨ .-**

ចំណាយនៃ **ភាមិនភ្វ** រួមមាន :

-ចំណាយប្រក្រតីសម្រាប់ដំណើរការ

-ចំណាយវិនិយោគ

-ចំណាយសងបំណុល

-ចំណាយផ្សេងៗ ។

**មាត្រា ១៩ .-**

**ភាមិនភ្វ** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់ តំរូវការរបស់ខ្លួន ។

**មាត្រា ២០ .-**

**កាមិនកូ** ត្រូវបង់ប្រាក់ចំណេញពិតប្រចាំឆ្នាំ ចូលថវិការដ្ឋចំនួន ៧០% ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះទាំងអស់ឱ្យសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍជាចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ **កាមិនកូ** មានសិទ្ធិប្រើប្រាស់ឱ្យស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា ២១ .-**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២ .-**

រយៈពេល ១៥ ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **កាមិនកូ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ :

-កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

-គម្រោងផែនការរបស់ **កាមិនកូ**

-របាយការណ៍ស្តីពីសកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **កាមិនកូ** ។

**មាត្រា ២៣ .-**

ត្រូវបានដាក់ឱ្យនៅអម **កាមិនកូ** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវបានតែងតាំង ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់ លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ២០ ដល់មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៥
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៥៣៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ សុវត្ថារា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយ សុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **ទេព ដារ៉ុង** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ក្នុងឆ្នាំ ២០០១ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៣៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយ ការងារ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ៧៨ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ក្នុងឆ្នាំ ២០០១ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសការងារ :**

១-ឯកឧត្តម **យិន ចន** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
២-ឯកឧត្តម **ជាច សាវី** ស្មើអគ្គនាយក នៃខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
៣-ឯកឧត្តម **ស៊ុំ ឈុំប៊ុន** សមាជិករាជបណ្ឌិតសភា
៤-លោក **លី គឹមឡុង** ប្រធាននាយកដ្ឋានគ្រឿងញៀន

**ខ_មេដាយប្រាក់ការងារ :**

១-លោកវរសេនីយ៍ឯក **ផាន់ ឆវិន្ទ** កងហោះដឹកជញ្ជូន
២-លោកវរសេនីយ៍ឯក **សូ ណារ៉ា** កងហោះដឹកជញ្ជូន
៣-លោកវរសេនីយ៍ទោ **គុយ សារិន** កងហោះដឹកជញ្ជូន
៤-កញ្ញា **នួល ចំនួជាវី** អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

៥-លោក ឡាង ស៊ីផន អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានឧស្សាហកម្ម រ៉ែនិងថាមពល
៦-លោក ម៉ែន យ៉ាន អនុប្រធាននាយកដ្ឋាននៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
៧-លោក សុខ ស៊ីឡុ ប្រធានផ្នែកនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
៨-លោក ត្រឹង លឹម ប្រធានផ្នែករដ្ឋបាលនៃរាជបណ្ឌិតសភា
៩-លោក ង៉ូ ច័ន្ទដារី ប្រធានផ្នែកបណ្តុះបណ្តាលនៃរាជបណ្ឌិតសភា
១០-លោក គង់ ចំរើន ជំនួយការអគ្គមេធាវី
១១-លោក សេង សត្ថា ជំនួយការនៃខុទ្ទកាល័យទេសរដ្ឋមន្ត្រី
១២-លោក ឈុន ថុង ជំនួយការនៃខុទ្ទកាល័យទេសរដ្ឋមន្ត្រី
១៣-លោក ខៀវ សេរីវិសិដ្ឋ ជំនួយការនៃខុទ្ទកាល័យទេសរដ្ឋមន្ត្រី
១៤-លោក ច័ន្ទ មនោ ស្មើប្រធាននាយកដ្ឋាននៃខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
១៥-លោក ឈួន ឆេង ស្មើប្រធាននាយកដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
១៦-លោក យិន ឈុន ស្មើប្រធាននាយកដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
១៧-កញ្ញា សម សុភាវា ស៊ីអនុប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

**គ. មេដាយសេនាអភ័យ៖**

១-លោក សំ មុនិណារ៉ា ប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
២-លោកស្រី លឹម ស៊ីដេពីន អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
៣-លោក សោម សាញ់ អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាល
៤-លោក គីម ស្រ៊ុង ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល
៥-លោក ពៅ សឿន អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល
៦-កញ្ញា ទៀល សុផេត អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល
៧-លោកស្រី ស សំណាង អនុប្រធានការិយាល័យ នៃនាយកដ្ឋានគមនាគមន៍
៨-លោក ហ៊ឹម វិបុលសុខ ប្រធានការិយាល័យនៃនាយកដ្ឋានអប់រំ
៩-លោក ឡុង សុខា ប្រធានការិយាល័យនៃនាយកដ្ឋានកសិកម្ម
១០-លោកស្រី អ៊ុំ ដាវី ប្រធានការិយាល័យនៃនាយកដ្ឋានតំកល់ឯកសារ
១១-លោក ម៉ម ឈារ៉ាន អនុប្រធានការិយាល័យនៃនាយកដ្ឋានតំកល់ឯកសារ
១២-លោក អ៊ិន សុខទើង អនុប្រធានការិយាល័យនៃនាយកដ្ឋានសេវាកុំព្យូទ័រ
១៣-លោក ហែម សឿន អនុប្រធានការិយាល័យនៃនាយកដ្ឋានសេវាកុំព្យូទ័រ
១៤-លោក សូ សារិន អនុប្រធានការិយាល័យនៃនាយកដ្ឋានសេវាកុំព្យូទ័រ
